# ជួយស្រុកកំណើតយើង

# (ជ.ស.យ)

# លក្ខន្តិកៈ

**អាសយដ្ឋានទំនាក់ទំនងៈ**

ផ្ទះលេខ ៤៣ ស្ទួន ក្រុមទី ៩ ភូមិ សន្សំកុសល ២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ

ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# មាតិកា

ទំព័រ

*****

បុព្វកថា....................................................................................................................................៣
ជំពូក ១ : អំពីឈ្មោះ ផ្លាកសញ្ញា អាសយដ្ឋាន និងកាលបរិច្ឆេទនៃការបង្កើត................................................ ៤
ជំពូក ២ : ទស្សនវិស័យ និងតម្លៃចំបង............................................................................................ ៥
ជំពូក ៣ : បេសកកម្ម គោលដៅ និងសកម្មភាពការងារ........................................................................... ៥
ជំពូក ៤ : អំពីរចនាសម្ព័ន្ធរបស់សមាគម.......................................................................................... ៦
ជំពូក ៥ : អំពីក្រុមប្រឹក្សាផ្តល់យោបល់ ប្រធានសមាគម អនុប្រធានសមាគម និងគណៈកម្មាធិការប្រតិបត្តិ.......... ៧
ជំពូក ៦ : សមាជិកភាពរបស់សមាគម.............................................................................................១០
ជំពូក ៧ : សិទ្ធិ និងកាតព្វកិច្ចនៃសមាជិករបស់សមាគម........................................................................ ១១
ជំពូក ៨ : ប្រភពមូលនិធិ និងសកម្មភាពហិរញ្ញវត្ថុ.............................................................................. ១១
ជំពូក ៩ : មហាសន្និបាតរបស់សមាគម............................................................................................ ១២
ជំពូក ១០ : អំពីការរំសាយសមាគម............................................................................................... ១២
ជំពូក ១១ : ការកែប្រែ និងការធ្វើវិសោធនកម្មលើលក្ខន្តិកៈ.....................................................................១៣
ជំពូក ១២ : អន្តរប្បញ្ញត្តិ..........................................................................................................១៣
ជំពូក ១៣ : អវសានប្បញ្ញត្តិ .......................................................................................................១៣

# បុព្វកថា

មនុស្សមួយចំនួន បានឃ្លាតចាកឆ្ងាយពីភូមិស្រុកទៅនៅកន្លែងថ្មីមួយ ឬចាកចេញទៅកាន់ប្រទេសថ្មីមួយទៀត ដើម្បីបំពេញការរៀនសូត្រ ឬប្រកបមុខរបរសម្រាប់អនាគតដ៏ភ្លឺស្វាងរបស់ខ្លួន។ គេសង្កេតឃើញ ភាគច្រើនពួកគេទាំងនោះមិនបានវិលត្រលប់ទៅស្រុកកំណើតរបស់ខ្លួនវិញទេ ដោយសារតែទីនោះមិនបានផ្តល់ឱកាសការងារ និងមុខរបរចិញ្ចឹមជីវិតដល់ពួកគេ។

តែទោះជាទៅដល់ទីណាក៏ដោយ ពួកគេតែងតែនឹកឃើញដល់ភូមិស្រុក ដែលជាកន្លែងផ្តល់កំណើត ជាកន្លែងដែលគេធំដឹងក្តី ជាកន្លែងដែលប្រជុំទៅដោយសាច់ញាតិបងប្អូនមិត្តភ័ក្តិ និងជាកន្លែងដែលបន្សល់ទុកនូវអនុស្សាវរីយ៍យ៉ាងច្រើនរាប់មិនអស់។ ម្យ៉ាងទៀត សេចក្តីស្រលាញ់និងការនឹករលឹកដល់ស្រុកកំណើត ជារឿងមួយដែលមិនអាចភ្លេចបាននៅក្នុងជីវិតរបស់គេ។ លើសពីនេះទៅទៀតនោះ ការអភិវឌ្ឍន៍ស្រុកកំណើត ការចង់ឃើញស្រុកកំណើតរីកចំរើនលូតលាស់ និងការរួមចំណែកជួយដល់ស្រុកកំណើត តែងមានជានិច្ចនៅក្នុងចិត្តគំនិតរបស់ពួកគេ។

បើយើងក្រលេកមើលទៅអតីតកាលវិញ យើងឃើញថា ប្រទេសកម្ពុជាធ្លាប់ជាមហានគរដ៏ល្បីល្បាញមួយនៅក្នុងតំបន់នាសម័យអង្គរដ៏រុងរឿង។ ជាអកុសល ដោយសារការបែកបាក់សាមគ្គីភ្នា និងសង្គ្រាមរ៉ាំរ៉ៃដែលបានកើតឡើងជាបន្តបន្ទាប់ បានធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចុះកិត្យានុភាពរបស់ខ្លួនបន្តិចម្តង១។ ជាពិសេស ឆ្លងកាត់សង្គ្រាមស៊ីវិលជាងពីរទសវត្សចុងក្រោយនេះ រឹតតែធ្វើឱ្យសង្គមខ្មែរកាន់តែធ្លាក់ចុះដុនដាប រហូតត្រូវបានគេចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតលើពិភពលោក។

បទពិសោធន៍ដ៏អាក្រក់នេះ បានបន្សល់ទុកឱ្យសង្គមខ្មែរបច្ចុប្បន្ននូវបញ្ហាជាច្រើន ដូចជា :

-មានការបាត់បង់ភាពទុកចិត្តគ្នា សេចក្តីស្រលាញ់ សាមគ្គីភាព និងមេត្តាករុណា

-មានការធ្លាក់ចុះលើផ្នែកសីលធម៌សង្គមគួរឱ្យកត់សំគាល់

-មានកង្វះខាតផ្នែកធនធានមនុស្ស ទាំងសមត្ថភាពនិងជំនាញ ហើយគុណភាពអប់រំនៅមានកំរិតទាប ជាពិសេសធនធានមនុស្សនៅតាមបណ្តាខេត្តសំរាប់អភិវឌ្ឍសហគមន៍ ដែលជាមូលដ្ឋានចំបងក្នុងការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។

ដើម្បីចូលរួមចំណែកក្នុងការស្តារនិងអភិវឌ្ឍន៍ប្រទេសជាតិយើងឡើងវិញ និងដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ ព្រមទាំងដើម្បីឱ្យអ្នកដែលមានគំនិតចង់ជួយស្រុកកំណើតបានសម្រេចតាមគោលបំណងរបស់ខ្លួន យើងទាំងអស់គ្នាបានផ្តួចផ្តើមបង្កើតជាសមាគមមួយដែលមានឈ្មោះថា **"ជួយស្រុកកំណើតយើង"** ដែលមានលក្ខន្តិកៈដូចតទៅ :

# ជំពូក ១

## អំពីឈ្មោះ ផ្លាកសញ្ញា អាសយដ្ឋាន និងកាលបរិច្ឆេទនៃការបង្កើត

**មាត្រា១ :** អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងមិនជាប់ពាក់ព័ន្ធនឹងនយោបាយដែលមានឈ្មោះថា **"ជួយស្រុកកំណើតយើង"** គឺជាសមាគមដែលត្រូវបានបង្កើតឡើងតាមរយៈលទ្ធផលនៃការសំរេចចិត្តដោយសេរី ដោយយកអត្ថប្រយោជន៍រួមជាគោលសំរាប់អ្នកមកពីខេត្តដូចៗគ្នា ដែលជាស្រុកកំណើតរបស់ពួកគេ។

**មាត្រា២ :** ឈ្មោះរបស់សមាគមគឺ :

១- ឈ្មោះពេញជាភាសាខ្មែរគឺ **"ជួយស្រុកកំណើតយើង"**

២- ឈ្មោះពេញជាភាសាអង់គ្លេសគឺ "**Help Our Homeland**"

**មាត្រា៣ :** ឈ្មោះជាអក្សរកាត់របស់សមាគមនេះជាភាសារខ្មែរគឺ **"ជ.ស.យ"**

**មាត្រា៤ :** ឈ្មោះជាអក្សរកាត់របស់សមាគមនេះជាភាសាអង់គ្លេសគឺ "**HOH**"

**មាត្រា៥ :** រូបសញ្ញាសំគាល់របស់សមាគម មានរាងជាផ្ទះ ដែលមានអក្សរ **HOH** នៅចំកណ្តាល។

រូបសញ្ញានេះមានអត្ថន័យដូចខាងក្រោម :

-រូបសញ្ញាទាំងមូលដែលមានរាងជាផ្ទះ តំណាងឱ្យ ស្រុកកំណើតរបស់យើង។

-**HOH** គឺជាអក្សរកាត់ជាភាសាអង់គ្លេស ដែលមកពីពាក្យពេញថា : "**Help Our Homeland**" ហើយមានន័យជាភាសាខ្មែរថា **"ជួយស្រុកកំណើតយើង"** ។

**មាត្រា៦ :** សមាគមមានទីតាំងនៅផ្ទះលេខ ៤៣ ស្ទួន ក្រុមទី ៥ ភូមិសន្សំកុសល ២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៧ :** សមាគមត្រូវបានបង្កើតឡើងជាផ្លូវការ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ ។

**មាត្រា៨ :** សមាគមនេះគឺជាអង្គភាពស្ម័គ្រចិត្ត ក្រៅរដ្ឋាភិបាល និងឯករាជ្យដែលត្រូវបានរួមគ្នាបង្កើតឡើងក្នុងទម្រង់ជាសម្ព័ន្ធភាពមិនពាក់ព័ន្ធនឹងនយោបាយ និងមិនស្វែងរកប្រាក់ចំណេញ។ បុគ្គលគ្រប់រូបទទួលស្គាល់លក្ខន្តិកៈសមាគមនេះ និងមានឆន្ទៈក្នុងការផ្តល់ជំនួយនានាក្នុងការអភិវឌ្ឍន៍ស្រុកកំណើត។

**មាត្រា៩ :** សមាគមនេះអភិវឌ្ឍកម្មវិធីរបស់ខ្លួនដោយឯករាជ្យ និងអនុវត្តសកម្មភាពសាធារណៈ ដែលមានគោលដៅក្នុងការបំពេញទៅតាមភារៈកិច្ចរបស់ខ្លួនដូចដែលមានចែងនៅក្នុងលក្ខន្តិកៈ។

**មាត្រា១០ :** ប្រាក់ចំណូលនានា ដែលបានមកពីសកម្មភាពរបស់សមាគម មានគោលដៅក្នុងការបំពេញទៅតាមភារៈកិច្ចរបស់សមាគមគឺការអភិវឌ្ឍន៍ដល់សមាជិក និងស្រុកកំណើតរបស់ខ្លួន។

## ជំពូក ២

## ទស្សនវិស័យ និងតម្លៃចំបង

មាត្រា១១ : ទស្សនវិស័យរបស់សមាគមគឺ **"ភាពចំរុងចំរើនក្នុងស្រុកកំណើតយើងតាមរយៈបណ្តាញក្រុមការងារយើង"** ។

មាត្រា១២ : តម្លៃចំបងគឺ យើងខិតខំដើម្បីក្លាយខ្លួនទៅជាអង្គភាពមួយដែលទទួលបាននូវការពេញចិត្តបំផុតពីសង្គម និងអ្នកពាក់ព័ន្ធតាមរយៈ ÷

- **សេចក្តីស្រលាញ់**
- **សេចក្តីមេត្តាករុណា**
- **សាមគ្គីភាព**

## ជំពូក ៣

## បេសកកម្ម គោលដៅ និងសកម្មភាពការងារ

មាត្រា១៣ : បេសកកម្មរបស់សមាគម គឺចងក្រងបណ្តាញអ្នកដែលមកពីខេត្ត ដែលជាស្រុកកំណើតជាមួយគ្នា ដើម្បីជួយអភិវឌ្ឍស្រុកកំណើតរបស់ពួកគេ និងដើម្បីបង្កើនសាមគ្គីភាពរវាងគ្នានិងគ្នា ។

មាត្រា១៤ : គោលដៅ និងសកម្មភាពនានាមានដូចតទៅ:

**១- ការពង្រឹងសមត្ថភាព និងការបង្កើតបណ្តាញក្រុមការងារ**

- បង្កើតបណ្តាញទំនាក់ទំនងក្រុមការងារក្នុងចំណោមមិត្តភ័ក្តិមកពីខេត្តដូចគ្នា
- រៀបចំបណ្តាញទិន្នន័យ និងបែងចែកពត៌មានសំរាប់ទំនាក់ទំនងរបស់សមាជិកទាំងអស់
- រួមចំណែកបែងចែកចំណេះដឹង និងបទពិសោធន៍ក្នុងចំណោមសមាជិកក្រុម
- ជួយសមាជិកនានាឱ្យអស់ពីលទ្ធភាពតាមគ្រប់មធ្យោបាយទាំងអស់ដើម្បីសំរេចនូវគោលបំណងរបស់ពួកគេ
- បង្កើតឱ្យមាននូវការជួបជុំមិត្តភ័ក្តិ និងសកម្មភាពកំសាន្តនានា ដើម្បីពង្រីកចំណងមិត្តភាព
- ធ្វើឱ្យមានអភិបាលកិច្ចល្អ និងធានានូវការទទួលខុសត្រូវរាល់ធនធានទាំងអស់ដែលត្រូវបានផ្តល់ឱ្យដល់អង្គភាព ។

**២- ការលើកទឹកចិត្តដល់ការអប់រំ និងផ្នែកកីឡានៅតាមវិទ្យាល័យនានា**

- ធ្វើការជាមួយនាយកវិទ្យាល័យនានា និងស្ថាប័ននានា សំរាប់កម្មវិធីផ្តល់រង្វាន់ដល់សិស្សពូកែ និងកម្មវិធីប្រកួតកីឡា
- ផ្តល់រង្វាន់ដល់សិស្សពូកែនៅតាមវិទ្យាល័យជារៀងរាល់ឆ្នាំ

- រៀបចំកម្មវិធីប្រកួតកីឡាក្នុងចំណោមសិស្សវិទ្យាល័យរៀងរាល់មួយឆ្នាំម្តង ។

**៣- ពង្រឹងសមត្ថភាពធនធានមនុស្សសំរាប់ការអភិវឌ្ឍន៍សហគមន៍តាមមូលដ្ឋាន**

- ជួលមជ្ឈមណ្ឌលបណ្តុះបណ្តាល និងបំពាក់ឧបករណ៍ និងសំភារៈបណ្តុះបណ្តាល
- ស្វែងរកគ្រូបង្រៀន និងគ្រូបង្រៀនដែលស្ម័គ្រចិត្ត ឱ្យរៀបចំការបណ្តុះបណ្តាល
- ជ្រើសរើសសិស្សដែលមកពីវិទ្យាល័យនានាឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាល
- បង្កើតកម្មវិធីបណ្តុះបណ្តាល និងសំភារៈសំរាប់កម្មវិធីបណ្តុះបណ្តាលទាំងអស់ ។

**៤- ការបង្កើតការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន**

- បង្កើតក្រុមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានផ្សេងៗគ្នាជាច្រើនសំរាប់ស្រុកផ្សេងៗ ដែលពួកគេរស់នៅតាមរយៈអ្នកចូលរួមការបណ្តុះបណ្តាល ដែលបានជ្រើសរើស
- បន្តផ្តល់ការពង្រឹងសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន
- បង្កើនមូលនិធិ ដែលបានមកពីប្រភពនានាសំរាប់ក្រុមអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន
- ត្រួតពិនិត្យគុណភាព និងភាពរីកចំរើននៃកម្មវិធីអភិវឌ្ឍន៍ ។

**៥- ការបង្កើនមូលនិធិ និងបណ្តាញផ្តល់ជំនួយ**

- បង្កើតយុទ្ធសាស្ត្រសំរាប់សកម្មភាពបង្កើនមូលនិធិនានា
- បង្កើតទំនាក់ទំនងជាមួយអង្គភាពផ្តល់ជំនួយនានា ដែលអាចមាន
- បង្កើនមូលនិធិ ដែលបានមកពីបុគ្គល និងម្ចាស់ជំនួយនានា ។

## ជំពូក ៤

## អំពីរចនាសម្ព័ន្ធរបស់សមាគម

**មាត្រា១៥ :** រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងការងាររបស់សមាគម **ខ.ស.យ** គឺមាន **ក្រុមប្រឹក្សាផ្តល់យោបល់ ប្រធានសមាគម អនុប្រធានសមាគម** និង**គណៈកម្មាធិការប្រតិបត្តិ** ។

**មាត្រា១៦ :** សមាគមនេះមានស្នាក់ការកណ្តាលនៅក្រុងភ្នំពេញ និងអាចមានសាខានៅតាមបណ្តាខេត្ត-ក្រុងនីមួយៗ ។ **ក្រុមប្រឹក្សាផ្តល់យោបល់ ប្រធានសមាគម** និង**អនុប្រធានសមាគម** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការនៅភ្នំពេញ ។ អគ្គលេខាធិការដ្ឋាន មានការិយាល័យចំណុះចំនួន 0៦ គឺ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យគណនេយ្យ
- ការិយាល័យគំរោងសំណើ
- ការិយាល័យផ្សព្វផ្សាយ

- ការិយាល័យបណ្ដុះបណ្ដាល
- ការិយាល័យទំនាក់ទំនងសមាជិក និងម្ចាស់ជំនួយ

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១រូប ។

**គណៈកម្មាធិការប្រតិបត្តិ** ដែលជាសាខារបស់សមាគមនៅតាមបណ្ដាខេត្ត មានការិយាល័យចំនួន០៧គឺ :

- ការិយាល័យរដ្ឋបាល
- ការិយាល័យគណនេយ្យ និងបេឡា
- ការិយាល័យទំនាក់ទំនងសមាជិក និងម្ចាស់ជំនួយ
- ការិយាល័យផ្សព្វផ្សាយ
- ការិយាល័យអប់រំ និង បណ្ដុះបណ្ដាល
- ការិយាល័យកីឡា
- ការិយាល័យអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ០១រូប ។

# ជំពូក ៥

## អំពីក្រុមប្រឹក្សាផ្ដល់យោបល់ ប្រធានសមាគម អនុប្រធានសមាគម និងគណៈកម្មាធិការប្រតិបត្តិ

**មាត្រា១៧ :** ចំនួនសមាជិកក្រុមប្រឹក្សាផ្ដល់យោបល់ត្រូវមានចំនួនយ៉ាងតិច ០៥រូប ហើយដឹកនាំដោយប្រធានមួយរូប ដែលត្រូវបានជ្រើសរើសឡើងដោយសមាជិកក្រុមប្រឹក្សាផ្ដល់យោបល់ តាមសំលេងភាគច្រើនដាច់ខាតនៃសមាជិកចូលរួមប្រជុំ។ ការប្រជុំរបស់ក្រុមប្រឹក្សាផ្ដល់យោបល់អាចប្រព្រឹត្តិទៅបាន លុះត្រាតែមានកូរ៉ុមយ៉ាងតិច ៧/១០។ អាណត្តិរបស់ប្រធានក្រុមប្រឹក្សាផ្ដល់យោបល់មានរយៈពេល ០២ឆ្នាំ ហើយអាចឈរឈ្មោះនៅអាណត្តិបន្តបន្ទាប់ទៀតបាន។

**មាត្រា១៨ :** សមាជិកក្រុមប្រឹក្សាផ្ដល់យោបល់ដែលត្រូវជ្រើសរើសបំពេញ ឬ បន្ថែម ត្រូវធ្វើឡើងតាមរយៈអង្គប្រជុំរបស់ក្រុមប្រឹក្សាផ្ដល់យោបល់ខ្លួនឯង។

**មាត្រា១៩ : តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាផ្ដល់យោបល់**

ក្រុមប្រឹក្សាផ្ដល់យោបល់មានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោមៈ

- ដើរតួនាទីក្នុងការផ្ដល់យោបល់ សម្របសម្រួល និងណែនាំដល់ប្រធានសមាគម និងគណៈកម្មាធិការប្រតិបត្តិឱ្យអនុវត្តស្របទៅតាមគោលនយោបាយ និងសកម្មភាពរបស់សមាគម ហើយមានសិទ្ធិពេញលេញក្នុងការការពារសមាគមពីការប្រើប្រាស់ខុសក្នុងទម្រង់ណាមួយ ដែលងាកចេញពីទស្សន-

វិស័យ គោលដៅ និងសកម្មភាពនានារបស់សមាគម ដើម្បីធានាឱ្យមានការគោរពតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសមាគម

- ធ្វើការផ្តល់យោបល់លើការពង្រីក និងលើការបើកសាខាបន្ថែមតាមបណ្តាខេត្ត
- ជួយប្រធានសមាគម និងគណៈកម្មាធិការប្រតិបត្តិក្នុងការលើកសំណើសុំជំនួយ ស្វែងរកមូលនិធិ និងបង្កើតទំនាក់ទំនង ជាមួយសហគមន៍ជាតិ និងអន្តរជាតិ
- អាចចាត់តាំងឱ្យមានការត្រួតពិនិត្យ និងវាយតំលៃស្ថានភាពហិរញ្ញវត្ថុរបស់សមាគម ដោយភ្នាក់ងារមកពីខាងក្រៅណាមួយ
- ជ្រើសរើសសមាជិកក្រុមប្រឹក្សាផ្តល់យោបល់ និងប្រធានក្រុមប្រឹក្សាផ្តល់យោបល់
- ប្រធានក្រុមប្រឹក្សាផ្តល់យោបល់មានតួនាទីត្រួតពិនិត្យ និងសំរេចទៅលើរបៀបវារៈនៃការប្រជុំរបស់ក្រុមប្រឹក្សាផ្តល់យោបល់
- ប្រធានក្រុមប្រឹក្សាផ្តល់យោបល់ត្រូវធ្វើការដឹកនាំអង្គប្រជុំនានា និងកោះអញ្ជើញសមាជិកក្រុមប្រឹក្សាឱ្យចូលរួមក្នុងអង្គប្រជុំសាមញ្ញដែលប្រព្រឹត្តទៅមួយត្រីមាសម្តង និងអង្គប្រជុំវិសាមញ្ញតាមការស្នើសុំរបស់ប្រធាន ឬ១/៣នៃសមាជិកក្រុមប្រឹក្សាផ្តល់យោបល់ ឬពីប្រធានសមាគម។

**មាត្រា២០ : ប្រធានសមាគមមានតួនាទី និងភារកិច្ចដូចខាងក្រោម :**

- ជាតំណាងរបស់សមាគម
- ដឹកនាំ ត្រួតពិនិត្យ និងទទួលខុសត្រូវលើការអនុវត្តន៍រាល់សកម្មភាពការងារទាំងអស់ ស្របទៅតាមទស្សនវិស័យ និងគោលដៅរបស់សមាគម
- ធ្វើសំណើសុំជំនួយ ស្វែងរកមូលនិធិ និងបង្កើតទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិ
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារ ហិរញ្ញវត្ថុ និងស្ថិតិប្រចាំឆ្នាំ ព្រមទាំងគំរោងសំណើសុំជំនួយដល់មហាសន្និបាត និងដល់ក្រុមប្រឹក្សាផ្តល់យោបល់
- តែងតាំងតំណែងនានាក្នុងសមាគមពេលចាំបាច់ដូចជា អនុប្រធានសមាគម សមាជិករបស់អគ្គលេខា-ធិការដ្ឋាន និងបុគ្គលិកដទៃទៀត ទៅតាមតម្រូវការចាំបាច់របស់សមាគម និងកំណត់អំពីបៀវត្សរ៍សមស្រប ក្រោយពីបានពិភាក្សា និងបានការយល់ព្រមពីប្រធានក្រុមប្រឹក្សាផ្តល់យោបល់
- កោះអញ្ជើញគណៈកម្មាធិការប្រតិបត្តិទាំងអស់ឱ្យចូលរួមក្នុងកិច្ចប្រជុំ ដោះស្រាយបញ្ហាពិសេសណាមួយក្នុងករណីចាំបាច់
- ជាអធិបតីក្នុងកិច្ចប្រជុំរួមរបស់គណៈកម្មាធិការប្រតិបត្តិ និងមហាសន្និបាត
- ត្រួតពិនិត្យ និងគ្រប់គ្រងលើរាល់សកម្មភាពនៃការអនុវត្តការងារ និងការចំណាយ
- ធ្វើការណែនាំ និងសំរេចលើការប្រព្រឹត្តិខុសរបស់សមាជិកស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង

- ត្រូវធានាថា សកម្មភាពនានារបស់សមាគមមិនផ្ទុយនឹងច្បាប់ដែលមានជាធរមាន ឬប៉ះពាល់ដល់សីលធម៌សង្គម។

**មាត្រា២១ :** ប្រធានសមាគមមានអាណត្តិ២ឆ្នាំ ហើយត្រូវបានជ្រើសរើសឡើងនៅក្នុងមហាសន្និបាត តាមរយៈការបោះឆ្នោតដោយសំលេង ២/៣ នៃអ្នកមានវត្តមាននៅក្នុងមហាសន្និបាត។ អនុប្រធានសមាគមមានអាណត្តិស្មើនឹងអាណត្តិប្រធានសមាគម និងអាចត្រូវបានជ្រើសតាំងសាជាថ្មីឡើងវិញបាន។ អនុប្រធានសមាគម មានតួនាទីជួយដល់ប្រធានសមាគម និងជំនួសកិច្ចការរបស់ប្រធានសមាគម ពេលមានការផ្ទេរសិទ្ធិពីប្រធានសមាគម។

**មាត្រា២២ :** បុគ្គលដែលអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាប្រធានសមាគម ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

- មានសញ្ជាតិជាខ្មែរ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ
- មិនមានទំនាក់ទំនងជាមួយគណបក្សនយោបាយណាមួយឡើយ
- មិនមែនជាប្រធានក្រុមប្រឹក្សាផ្តល់យោបល់
- មានសញ្ញាប័ត្របរិញ្ញាប័ត្រឡើងទៅ
- មានបទពិសោធន៍ការងារយ៉ាងតិច ២ឆ្នាំ
- មានកិត្តិនាម និងសីលធម៌ល្អ។

**មាត្រា២៣ :** ក្នុងករណីចង់លាលែងចេញពីតំណែង ប្រធានសមាគមត្រូវផ្តល់ដំណឹងដល់ក្រុមប្រឹក្សាផ្តល់យោបល់ក្នុងរយៈពេលមួយខែជាមុន។ ប្រធានក្រុមប្រឹក្សាផ្តល់យោបល់ត្រូវចាត់ចែងឱ្យមានកិច្ចប្រជុំពិសេសរួមគ្នាមួយរវាងក្រុមប្រឹក្សាផ្តល់យោបល់ និងប្រធានគណៈកម្មាធិការប្រតិបត្តិទាំងអស់ ដើម្បីរើសប្រធានសមាគមថ្មីឱ្យបានទាន់ក្នុងរយៈពេលខាងលើ។ ប្រធានសមាគមថ្មីត្រូវកាន់តំណែងសំរាប់កំឡុងពេលដែលនៅសល់។

**មាត្រា២៤ :** គណៈកម្មាធិការប្រតិបត្តិតាមខេត្តនីមួយៗ មានចំនួនសមាជិកយ៉ាងតិច ០៨រូប ដែលមួយរូបជាប្រធាន។ គណៈកម្មាធិការប្រតិបត្តិ ត្រូវបានជ្រើសរើសក្នុងកំឡុងពេល ០២ឆ្នាំម្តង ដោយសមាជិកសមាគមតាមខេត្តនីមួយៗ ដោយមតិភាគច្រើនដាច់ខាត។

**មាត្រា២៥ :** គណៈកម្មាធិការប្រតិបត្តិ គឺជាសាខារបស់សមាគមនៅតាមបណ្តាខេត្ត។ គណៈកម្មាធិការប្រតិបត្តិក្នុងខេត្តនិមួយៗ គឺជាអង្គភាពដឹកនាំនៅក្នុងស្រុកកំណើតរបស់ពួកគេ ហើយមានសិទ្ធិពេញលេញក្នុងការសំរេច និងអនុវត្តសកម្មភាពនានា ស្របទៅតាមទស្សនវិស័យ និងគោលដៅរបស់សមាគម។

**មាត្រា២៦ : តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិ**

គណៈកម្មាធិការប្រតិបត្តិមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម:

- ដឹកនាំ និងទទួលខុសត្រូវនូវការប្រតិបត្តិ តាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម

- ធ្វើការសំរេចទទួលយក ឬបដិសេធមិនទទួលយកលើការដាក់ពាក្យសុំចូលជាសមាជិកសមាគម និងជាអ្នកសំរេចលើការបញ្ឈប់សមាជិកភាពរបស់សមាគម បន្ទាប់ពីមានការយល់ព្រមពីប្រធានសមាគម
- ពិចារណា និងបង្ហាញនូវផែនការការងារលើសកម្មភាពរបស់សមាគមដល់កិច្ចប្រជុំរួមទូទៅ
- ធ្វើសំណើ និងស្វែងរកមូលនិធិដើម្បីទ្រទ្រង់អង្គភាពរបស់ខ្លួន
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារ ហិរញ្ញវត្ថុ និងស្ថិតិប្រចាំឆ្នាំ ព្រមទាំងគំរោងសំណើសុំជំនួយដល់ប្រធានសមាគមដើម្បីដាក់ចូលរបៀបវារៈកិច្ចប្រជុំប្រចាំឆ្នាំ
- តែងតាំងតំណែងនានាក្នុងអង្គភាពខ្លួនពេលចាំបាច់ដូចជា គណនេយ្យករ លេខាធិការ និងបុគ្គលិកដទៃទៀត ទៅតាមតម្រូវការចាំបាច់របស់អង្គភាពខ្លួន
- ត្រួតពិនិត្យ និងគ្រប់គ្រងលើសកម្មភាពនៃការអនុវត្តការងារ និងរាល់ការចំណាយ
- ណែនាំ និងដាក់ទណ្ឌកម្មលើសមាជិកក្រោមឱវាទស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ដឹកនាំអង្គប្រជុំ និងកោះអញ្ជើញសមាជិករបស់សមាគមឱ្យចូលរួមក្នុងកិច្ចប្រជុំនានា និងកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិ ។

**មាត្រា២៧ :** គណៈកម្មាធិការប្រតិបត្តិមានសិទ្ធិចេញនូវសេចក្ដីសំរេចនានាក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ដោយយកតាមសំលេងភាគច្រើនដាច់ខាតនៃសមាជិកវត្តមាន។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងរបស់ប្រធានមានឧត្តមានុភាព។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកយ៉ាងតិច ៧/១០ ចូលរួម។ រាល់សេចក្ដីសំរេចរបស់គណៈកម្មាធិការប្រតិបត្តិត្រូវមានហត្ថលេខារបស់ប្រធាន។

**មាត្រា២៨ :** គណៈកម្មាធិការប្រតិបត្តិជាធម្មតាជួបប្រជុំយ៉ាងតិចម្ដងក្នុងមួយខែ ដើម្បីធ្វើការដោះស្រាយបញ្ហាដែលកើតមានក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន និងដើម្បីស្វែងរកយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍន៍សមាគម។

# ជំពូក ៦

## សមាជិកភាពរបស់សមាគម

**មាត្រា២៩ :** **ខ.ស.យ** មានសមាជិកភាពពីរប្រភេទគឺ **សមាជិកសកម្ម** និង **សមាជិកកិត្តិយស** ។

**មាត្រា៣០ :** ប្រធានសមាគមមានសិទ្ធិក្នុងការចាត់ថ្នាក់ប្រភេទសមាជិកភាព ដោយយោងទៅតាមលក្ខន្តិកៈសមាគម។

**មាត្រា៣១ :** ប្រធានសមាគម និងគណៈកម្មាធិការប្រតិបត្តិ មានសិទ្ធិសំរេចបញ្ចូល និងបញ្ឈប់សមាជិកភាព។

**មាត្រា៣២ :** **សមាជិកសកម្ម** គឺជាម្ចាស់ជំនួយទាំងឡាយណាដែលផ្ដល់វិភាគទានដោយស្ម័គ្រចិត្តជាប្រចាំដល់សមាគម ឬចូលរួមក្នុងសកម្មភាពរបស់សមាគមដោយផ្ទាល់។

**មាត្រា៣៣ :** **សមាជិកកិត្តិយស** ជាម្ចាស់ជំនួយទាំងឡាយណាដែលធ្លាប់បានផ្ដល់វិភាគទានដោយស្ម័គ្រចិត្តដល់សមាគម ឬចូលរួមគាំទ្រដល់សកម្មភាពសមាគម។

**មាត្រា៣៤ :** សមាជិករបស់សមាគមដែលមិនអាចបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងលក្ខន្តិកៈ ឬកាតព្វកិច្ចរបស់ខ្លួន ឬអ្នកដែលបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៏របស់សមាគម នឹងត្រូវបញ្ឈប់ពីសមាគមស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម ។

# ជំពូក ៧

## សិទ្ធិ និងកាតព្វកិច្ចនៃសមាជិករបស់សមាគម

**មាត្រា៣៥ :** សមាជិករបស់សមាគមមានសិទ្ធិ :

១-បោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតធ្វើជាអ្នកដឹកនាំក្នុងគណៈកម្មាធិការប្រតិបត្តិ

២- បញ្ចេញយោបល់លើការធ្វើឱ្យប្រសើរឡើងនូវសកម្មភាពរបស់សមាគម

៣- ទទួលបានប្រយោជន៍ពីសកម្មភាពនានារបស់សមាគម

**មាត្រា៣៦ :** សមាជិករបស់សមាគមត្រូវមានកាតព្វកិច្ច :

១- ទទួលស្គាល់សេចក្តីសំរេចនានារបស់អ្នកដឹកនាំសមាគម

២- ចូលរួមចំណែកក្នុងកិច្ចការនានារបស់សមាគម

៣- ទទួលខុសត្រូវចំពោះការខូចខាតនានាដល់សមាគមស្របទៅតាមវិន័យ និងបទបញ្ជារបស់សមាគម និងរបស់អាជ្ញាធរមានសមត្ថកិច្ច

៤- បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគម ។

# ជំពូក ៨

## ប្រភពមូលនិធិ និងសកម្មភាពហិរញ្ញវត្ថុ

**មាត្រា៣៧ :** មធ្យោបាយស្វែងរកហិរញ្ញវត្ថុរបស់សមាគម បានមកពីប្រភពមូលនិធិដូចខាងក្រោមៈ

- ការបរិច្ចាគរបស់សមាជិកសកម្ម និងសមាជិកដទៃទៀតរបស់សមាគម
- ការបរិច្ចាគរបស់សប្បុរសជននានា អង្គការជាតិ-អន្តរជាតិនានា
- ការបរិច្ចាគរបស់ក្រុមហ៊ុនឯកជន
- ចំណូលពីការបណ្តុះបណ្តាលនានា
- និងប្រភពមូលនិធិស្របច្បាប់ផ្សេងៗទៀត

**មាត្រា៣៨ : មូលនិធិរបស់សមាគម ត្រូវបានប្រើប្រាស់សំរាប់គោលបំណងដូចខាងក្រោមៈ**

- ធានានូវសកម្មភាពរបស់សមាគម និងបំពេញតាមគោលដៅដែលមានចែងក្នុងលក្ខន្តិកៈរបស់សមាគម
- ចំណាយលើបៀវត្សរ៍របស់បុគ្គលិក និងថ្នាក់ដឹកនាំសមាគម

- រៀបចំកិច្ចប្រជុំទូទៅ និងកម្មវិធីផ្សេងៗ
- ចំណាយលើសកម្មភាពនានារបស់សមាគម ដើម្បីធានានិរន្តភាពរបស់សមាគម និង
- សកម្មភាពនានារបស់សមាគមដែលមិនបានចែងនៅក្នុងលក្ខន្តិកៈប្រសិនបើចាំបាច់។

**មាត្រា៣៩ :** អ្នកដែលមានសិទ្ធិសំរេចក្នុងការចាយវាយហិរញ្ញវត្ថុរបស់សមាគម មាន :

- ប្រធានក្រុមប្រឹក្សាផ្តល់យោបល់
- ប្រធានសមាគម និងអនុប្រធានសមាគម
- ប្រធានគណៈកម្មាធិការប្រតិបត្តិ
- គណនេយ្យកររបស់សមាគម និងគណនេយ្យកររបស់គណៈកម្មាធិការប្រតិបត្តិ

ការប្រព្រឹត្តទៅនៃហិរញ្ញវត្ថុសមាគម នឹងមានចែងបន្ថែមលំអិតនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់សមាគម។

## ជំពូក ៩

## មហាសន្និបាតរបស់សមាគម

**មាត្រា៤០ :** ក្រុមប្រឹក្សាផ្តល់យោបល់ និងប្រធានសមាគម ជាអ្នកសំរេចកំណត់ពេលវេលា និងរបៀបវារៈរបស់មហាសន្និបាតដែលត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។ មហាសន្និបាត នឹងត្រូវដឹកនាំដោយប្រធានសមាគម ហើយត្រូវចូលរួមដោយក្រុមប្រឹក្សាផ្តល់យោបល់ អនុប្រធានសមាគម សមាជិកអគ្គលេខាធិការដ្ឋាន និងសមាជិករបស់គណៈកម្មាធិការប្រតិបត្តិទាំងអស់។

**មាត្រា៤១ :** មហាសន្និបាតមានគោលដៅ :

១-សរុបរបាយការណ៍ស្តីពីសកម្មភាពការងារ និងសកម្មភាពនានាដែលបានបំពេញ ដោយរាប់បញ្ចូលទាំងសកម្មភាពហិរញ្ញវត្ថុរបស់សមាគម

២-លើកផែនការជាយុទ្ធសាស្ត្រសំរាប់ការអនុវត្តការងារជាបន្តទៀត និងបញ្ហាផ្សេងៗទៀត។

៣-បោះឆ្នោតជ្រើសរើសប្រធានសមាគម សំរាប់រយៈពេល ០២ឆ្នាំម្តង។

## ជំពូក ១០

## អំពីការរំលាយសមាគម

**មាត្រា៤២ :** សមាគមអាចរំលាយទៅបានលុះណាតែមានការស្នើសុំពីប្រធានសមាគម ឬស្នើពីក្រុមប្រឹក្សាផ្តល់យោបល់ ដោយសំលេងយ៉ាងតិច២/៣ ហើយត្រូវអនុម័តដោយការប្រជុំមហាសន្និបាតវិសាមញ្ញក្នុងសំលេងយល់ព្រម ២/៣នៃចំនួនសមាជិកវត្តមាន ដោយការបោះឆ្នោតសំងាត់។

**មាត្រា៤៣ :** ក្នុងករណីមានការរំសាយសមាគម ទ្រព្យសម្បត្តិ សំភារៈឧបករណ៍ទាំងឡាយរបស់ **ខ.ស.យ** នឹងត្រូវបែងចែក ឬផ្ទេរទៅឱ្យអង្គការខ្មែរក្រៅរដ្ឋាភិបាល ឬសមាគមខ្មែរនៅក្នុងស្រុក ដែលមានទិសដៅ ឬកម្មវិធីប្រហាក់ប្រហែលនឹងទិសដៅនិងកម្មវិធីរបស់ **ខ.ស.យ**។

## ជំពូក ១១
## ការកែប្រែ និងការធ្វើវិសោធនកម្មលើលក្ខន្តិកៈ

**មាត្រា៤៤ :** លក្ខន្តិកៈអាចត្រូវបានកែប្រែ ឬធ្វើវិសោធនកម្មបាន ប្រសិនបើយល់ឃើញថាចាំបាច់ ឬតាមការស្នើឡើងរបស់ប្រធានសមាគម ឬប្រធានក្រុមប្រឹក្សាផ្តល់យោបល់ ឬ១/៣នៃសមាជិកក្រុមប្រឹក្សាផ្តល់យោបល់។ ការសំរេចយល់ព្រមលើការកែប្រែ ឬធ្វើវិសោធនកម្មត្រូវអនុម័តតាមមតិ២/៣នៃចំនួនសមាជិកវត្តមានក្នុងកិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ។

**មាត្រា៤៥ :** ការកែប្រែ និងការធ្វើវិសោធនកម្មលើលក្ខន្តិកៈរបស់សមាគម មិនអាចធ្វើឡើងបានឡើយ ប្រសិនបើប៉ះពាល់ដល់ទស្សនវិស័យ និងគោលដៅរបស់សមាគមដូចមានចែងក្នុងមាត្រា១១-១២-១៣ និង១៤។

## ជំពូក ១២
## អន្តរប្បញ្ញត្តិ

**មាត្រា៤៦ :** នៅក្នុងអាណត្តិដំបូងនេះ ក្រុមប្រឹក្សាផ្តល់យោបល់មានសមាជិកចំនួន ០៥រូប ដែលជ្រើសចេញពីអ្នកដែលផ្តួចផ្តើមបង្កើតសមាគម ហើយអាណត្តិរបស់ប្រធានក្រុមប្រឹក្សាផ្តល់យោបល់ មានរយៈពេល ០៣ឆ្នាំ ។

**មាត្រា៤៧ :** ក្នុងស្ថានភាពដែលសមាគមនេះទើបត្រូវបានបង្កើតឡើង ក្រុមប្រឹក្សាផ្តល់យោបល់ ត្រូវធ្វើការជ្រើសតាំងប្រធានសមាគម អនុប្រធានសមាគម សមាជិកអគ្គលេខាធិការដ្ឋាន និងគណៈកម្មាធិការប្រតិបត្តិប្រចាំខេត្តកំពង់ធំ សំរាប់អាណត្តិ ០២ឆ្នាំ ដើម្បីឱ្យមានការចាប់ផ្តើមសកម្មភាពរបស់សមាគមបានឆាប់រហ័ស។

**មាត្រា៤៨ :** នៅពេលមានការបើកសាខាតាមបណ្តាខេត្តនានាផ្សេងទៀត គណៈកម្មាធិការប្រតិបត្តិដំបូងប្រចាំខេត្តត្រូវជ្រើសរើសដោយក្រុមប្រឹក្សាផ្តល់យោបល់ដោយមតិភាគច្រើនសំរាប់អាណត្តិ ០២ឆ្នាំ។

## ជំពូក ១៣
## អវសានប្បញ្ញត្តិ

**មាត្រា៤៩ :** រាល់បទប្បញ្ញត្តិទាំងអស់របស់សមាគមដែលផ្ទុយនឹងលក្ខន្តិកៈនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៥០ :** លក្ខន្តិកៈនេះត្រូវបានអនុម័តយល់ព្រមដោយឯកឆន្ទពីក្រុមប្រឹក្សាផ្តល់យោបល់អាណ្តតិដំបូង នៅក្នុងកិច្ចប្រជុំនាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៤ និងបានធ្វើវិសោធនកម្មលើកទីមួយនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០៤ និងលើកទីពីរនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០៤។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៤

**ក្រុមប្រឹក្សាផ្តល់យោបល់**

**ប្រធាន**

**អោម សេខប៉ុរ៉ា**